ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ខេត្តកណ្ដាល ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២២
ក្រឡាបញ្ជី

[redacted]

សំណុំរឿងព្រហ្មទណ្ឌលេខ÷ ១៧៤០ អ.ក
ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១
សាលក្រមលេខ÷ ៧៣ (ខ)
ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

# សាលក្រមព្រហ្មទណ្ឌ

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល
នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក និងប្រកាសសាលក្រម
នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ÷

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល
លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងខេត្តកណ្ដាល
លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងខេត្តកណ្ដាល

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ១៧៤០ អ.ក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ មានជនជាប់ចោទ÷

១. ឈ្មោះ [redacted]តាយ ហៅតាយ ភេទប្រុស កើតឆ្នាំ១៩៨២ (អាយុ៤០ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ ជាងសំណង់ ទីកន្លែងកំណើតនៅ[redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ស្រេង (ស្លាប់) ម្ដាយឈ្មោះ [redacted] សួយ (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ធីយឹម ឬ [redacted] ធីយ៉ាង (រស់) មានកូនចំនួន០២នាក់ ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៣ ទោសពីមុនគ្មាន។ (ឃុំខ្លួនថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១)

ត្រូវជាប់ចោទពីបទ÷ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីយ៉ាវ ភេទស្រី កើតឆ្នាំ១៩៨២ (អាយុ៣៧ឆ្នាំ) ជនជាតិវៀតណាម មុខរបរ មេផ្ទះ ទីកន្លែងកំណើតនៅឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិ៥ ឃុំព្រែកខ្សាយ ស្រុកពាមរក៍ ខេត្តព្រៃវែង ប្តីឈ្មោះ [redacted] ដាងជុង មានកូនចំនួន០៣នាក់ ជានីតិជន ។

-បានឃើញ ដីកាដំណោះស្រាយលេខ÷៤១១ ដកដស/២២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ÷៤៣៤ ដកចត/២២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ ÷**

កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ មានករណី **ឃាតកម្មគិតទុកជាមុន** ស្ថិតនៅចំណុចភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] តាយ ភេទប្រុស ដែលបានតេណាត់ជួបជនរងគ្រោះឈ្មោះ [redacted] ដាងជុង ភេទប្រុស មកជួបដើម្បីនិយាយពីរឿងការងារថ្មី ប៉ុន្តែជនរងគ្រោះបានឲ្យជនជាប់ចោទរងចាំជាច្រើនម៉ោង ទើបបណ្តាលឲ្យជនជាប់ចោទខឹង។ លុះក្រោយមក អ្នកទាំងពីរបានទៅកន្លែងណាត់ជួបពិភាក្សាការងារ ប៉ុន្តែជនរងគ្រោះបានប្រាប់ជនជាប់ចោទថា អ្នកដែលនិយាយការងារអត់មកទេ ទើបធ្វើឲ្យជនជាប់ចោទខឹង និងឈ្លោះគ្នា។ លុះដល់ម៉ោង ២០ និង៣០នាទី ជនរងគ្រោះបានឌុបជនជាប់ចោទបានចម្ងាយ៣,៥ គីឡូម៉ែត្រ ពីកន្លែងផឹកស៊ី ហើយជនរងគ្រោះបានឈប់នោមនៅចំណុចភូមិអំពិលទឹក ស្រាប់តែឈ្មោះ [redacted] តាយ បានយកកូនកាំបិតដងជ័រ ពណ៌លឿង ដែលលាក់ទុកក្នុងហោប៉ៅខោដែលត្រៀមជាស្រេចនោះ ចាក់ខ្នងជនរងគ្រោះចំនួន០១ (មួយ) កាំបិត ត្រូវចំដើមទ្រូងខាងឆ្វេងចំនួន០១ (មួយ) កាំបិត និងបានចាក់ពីលើខ្នងជាច្រើនកាំបិតទៀត បណ្តាលឲ្យជនរងគ្រោះស្លាប់ និងបានយកម៉ូតូជនរងគ្រោះទៅចោលក្នុងទឹកតែម្តង។ លុះដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ទើបកម្លាំងជំនាញកងរាជអាវុធហត្ថបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] តាយ និងកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី ។

**នាពេលសវនាការ ÷**

**១.** ជនជាប់ចោទឈ្មោះ [redacted] តាយ បានឆ្លើយថា÷ ខ្ញុំបាទ និងជនរងគ្រោះឈ្មោះ [redacted] ដាងជុង គឺជាមិត្តភក្តិនឹងគ្នាតាំងពីនៅតូច រហូតដល់បច្ចុប្បន្នក៏រកស៊ី ធ្វើការជាមួយគ្នាដែរ។ នៅថ្ងៃកើតហេតុ ខ្ញុំបាទ និងជនរងគ្រោះឈ្មោះ [redacted] ដាងជុង បានឈ្លោះប្រកែកគ្នារឿងការងារនៅកន្លែងហាងផឹកស៊ីមួយកន្លែង។ បន្ទាប់មក ជនរងគ្រោះបានជិះម៉ូតូឌុបខ្ញុំបាទចេញពីហាងផឹកស៊ីនោះសំដៅទៅផ្ទះវិញបានប្រហែលជា៥ប់នាទី ក៏ឈ្លោះគ្នាទៀត នឹងបានឈប់ម៉ូតូ ពេលនោះខ្ញុំបាទក៏បានវាយទៅលើជនរងគ្រោះចំនួនបីទៅបួនដៃ ហើយជនរងគ្រោះក៏បានយកមួកសុវត្ថិភាពវាយមកលើរូបខ្ញុំបាទវិញ។ ប៉ុន្តែខ្ញុំបាទមិន

បានយកកាំបិតចាក់ជនរងគ្រោះឡើយ។ ពេលខ្ញុំវាយជនរងគ្រោះបណ្តាលឱ្យដួលផ្កាប់មុខរួច ខ្ញុំបាទក៏លើកម៉ូតូរបស់ជនរងគ្រោះជិះទៅផ្ទះតែម្តង។ បន្ទាប់មក ខ្ញុំបាទបានយកម៉ូតូនោះទៅដាក់បញ្ចាំ ប៉ុន្តែដោយសារតែខ្លាចគេសង្ស័យ ខ្ញុំបាទក៏យកម៉ូតូនោះទៅទំលាក់ទឹកចោល។ ខ្ញុំបាទសូមបដិសេធចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច, ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរចោលទាំងស្រុង។ នៅក្នុងរឿងនេះ ខ្ញុំបាទមិនធ្លាប់មានចេតនាចង់សំលាប់ជនរងគ្រោះឡើយ។

២. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីយ៉ាវ ថា÷ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៧ព្រឹក ប្តីរបស់នាងខ្ញុំបានចេញពីផ្ទះជួលនៅម៉ុស្ទីងមានជ័យទៅដើរម៉ៅការសំណង់។ លុះនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង១៨ និង០០នាទី ប្តីរបស់នាងខ្ញុំបានទាក់ទងមកតាមរយៈទូរស័ព្ទដោយប្រាប់ថា ណាត់ជួបគេនៅម៉ុស្តានលេខ៩ (ផ្លូវជាតិលេខ៦A) ខណ្ឌជ្រោយចង្វា និងបាននិយាយរឿងការងារម៉ៅការសំណង់រហូតដល់ម៉ោង២០ និង០០នាទី។ នាងខ្ញុំបានទាក់ទងទៅប្តីម្តងទៀតតាមរយៈ វីដេអូខល ដោយពេលនោះប្តីរបស់នាងខ្ញុំបានបើកវីដេអូឱ្យខ្លួនមើលនៅពេលកំពុងបើកម៉ូតូដែរ តែដោយមានភាពងងឹត ទើបមើលមិនឃើញមុខប្តីរបស់នាងខ្ញុំ ទើបនាងខ្ញុំបានបិទវីដេអូខលទៅ។ បន្ទាប់មកនាងខ្ញុំបានតេទូរស័ព្ទទៅប្តីម្តងទៀតចូល តែមិនបានលើកឡើយ រហូតដល់ព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ទើបនាងខ្ញុំដឹងថាប្តីរបស់ខ្លួនបានស្លាប់បាត់ទៅហើយ។

៣. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ហុងញ៉ុង ថា÷ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង២១ និង៣០នាទី ខណៈពេលកំពុងធ្វើបុណ្យសពឱ្យបងប្រុសបង្កើតស្រាប់តែឈ្មោះ ធា បានមកប្រាប់ខ្ញុំថា គាត់បានលឺប្រពន្ធរបស់ឈ្មោះ តាយ និយាយថា យប់មិញប្តីមកផ្ទះយប់ជ្រៅ ហើយខ្លួនមានប្រឡាក់ផុកពេញ ដោយឈ្មោះ ធា បានមកប្រាប់ខ្ញុំផ្ទាល់។ បន្ទាប់មក បងស្រីរបស់ឈ្មោះ តាយ បាននិយាយជាមួយឈ្មោះ តាយ នៅចំពោះមុខម្តាយរបស់ខ្ញុំថា មើលអាជុងទៅ ត្រូវគេកាប់សម្លាប់ពេលដើរផឹក ហើយឯងប្រយ័ត្នគេកាប់សម្លាប់ដូចវាដែរ ហើយប្រពន្ធរបស់អាតាយឯងបានប្រាប់ថា យប់មិញអាតាយឯង ចូលផ្ទះម៉ោង១ ម៉ោង២ យប់ ហើយខ្លួនប្រឡាក់សុទ្ធតែផុក ទុកឱ្យប្រពន្ធយំឡើងហើមភ្នែក។ ក្រោយពេលលឺដូច្នេះ ម្តាយរបស់នាងខ្ញុំ ដែលអង្គុយនៅជិតនោះ បានមកប្រាប់នាងខ្ញុំ ទើបនាងខ្ញុំបានរាយការណ៍ជូនសមត្ថកិច្ចតាមរយៈទូរស័ព្ទតែម្តង។

៤. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ធីយ៉ាង ហៅ [redacted] ថា÷ កាលពីព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ប្តីរបស់នាងខ្ញុំបានចេញពីផ្ទះ ដែលជាទម្លាប់គឺគាត់ទៅហូបបាយ និងកាហ្វេ ប៉ុន្តែមិនបានប្រាប់នាងខ្ញុំថាទៅណានោះទេ រហូតដល់ពេលល្ងាច ទើបប្តីនាងខ្ញុំត្រឡប់មកផ្ទះវិញ។ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ វេលាថ្ងៃត្រង់ ប្តីរបស់នាងខ្ញុំបានចេញពីផ្ទះមិនដឹងទៅណានោះទេ រហូតដល់ម៉ោង០៦ ល្ងាច ខ្ញុំក៏បានទាក់ទងទៅគាត់តាមទូរស័ព្ទ តែគាត់មិនបានទទួល ខ្ញុំក៏ព្យាយាមម្តងហើយម្តងទៀតរហូតដល់ពាក់កណ្តាលអាធ្រាត្រ គាត់នៅតែមិនទទួលទូរស័ព្ទខ្ញុំ។ មួយសន្ទុះក្រោយមក គាត់បានទូរស័ព្ទមកខ្ញុំវិញ តែនិយាយស្តាប់គ្នាមិនបានឡើយ។ លុះដល់វេលាម៉ោង០១ យប់រំលងអាធ្រាត្រ

ត្រ ឈានចូលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ទើបប្ដីរបស់នាងខ្ញុំត្រឡប់មកផ្ទះវិញដោយមានសភាពស្រវឹង និងជើងខោមានប្រឡាក់ភក់ ហើយនាងខ្ញុំក៏បានស្ដីបន្ទោសឱ្យគាត់បន្តិចបន្តួច រួចគាត់ប្រាប់ថា ពិបាកចិត្ត ពេកទើបផឹកស្រាបែបនេះ។

៥.ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] យ៉ាំងធៀន ថា÷ រូបខ្ញុំបាទ និង ឈ្មោះ [redacted] ដាងជុង ភេទប្រុស អាយុ៤០ឆ្នាំ សព្វថ្ងៃស្នាក់នៅសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជ ធានីភ្នំពេញ មានមុខរបរជាអ្នកម៉ៅការសំណង់។ សព្វថ្ងៃខ្ញុំបាទដឹងថាឈ្មោះ [redacted] ដាងជុង មានការដ្ឋាន សំណង់ចំនួន០២ (ពីរ) កន្លែង គឺនៅអរិយក្សត្រ ចំនួន០១ (មួយ) កន្លែង និងនៅជើងឯកចំការដូង ខណ្ឌ ដង្កោ រាជធានីភ្នំពេញ គឺធ្វើការ៉ស់សាំងចំនួន០១ (មួយ) កន្លែងទៀត។ ឈ្មោះ [redacted] ដាងជុង សព្វថ្ងៃរស់ នៅជាមួយប្រពន្ធឈ្មោះ [redacted] ធីយ៉ាវ ដោយរស់នៅផ្ទះជួល សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ។ ខ្ញុំបាទ ជាអ្នកគ្រប់គ្រងនៅក្នុងការដ្ឋានសំណង់នៅអរិយក្សត្រ ដោយឈ្មោះ [redacted] ដាងជុង ០៣ (បី) ទៅ០៤ (បួន) ថ្ងៃ ទើបមកមើលការដ្ឋានម្តង។ កូនជាងរបស់គាត់មានច្រើននាក់ និងមានមិត្តភ័ក្ត្រជាច្រើននាក់ ហើយខ្លះមានប្រើប្រាស់គ្រឿងញៀន។ ចំពោះពួកកូនជាងដែលប្រើប្រាស់គ្រឿងញៀន គឺខ្ញុំបាទដេញ ចេញអស់ហើយ ប៉ុន្តែខ្ញុំមិនដឹងថា ពួកគេនៅមានទំនាក់ទំនងជាមួយគ្នារឺអត់ទេ។ លុះដល់ថ្ងៃទី១១ ខែ តុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ ឈ្មោះ [redacted] ដាងជុង បានមកមើលការដ្ឋាននៅអរិយក្សត្រ រហូតដល់ម៉ោងប្រហែលដប់០៦ ទើបគាត់ត្រឡប់ទៅផ្ទះជួលវិញ ហើយរូបខ្ញុំមិនបានជួបគាត់ទៀតទេ។ រហូតដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៨ ព្រឹក ទើបដឹងថាឈ្មោះ [redacted] ដាងជុង ស្លាប់បាត់ ទៅហើយ។ កន្លងមក ខ្ញុំបានដឹងថាឈ្មោះ [redacted] ដាងជុង ឧស្សាហ៍ដើរផឹកស៊ីជាមួយឈ្មោះ លេន ភេទ ប្រុស អាយុប្រហែលជាង៣០ឆ្នាំ មុខរបរជាជាងការ៉ូ ជាមនុស្សញៀនថ្នាំ ហើយឧស្សាហ៍ឌុបឈ្មោះ [redacted] ដាងជុង ដើរផឹកស៊ី ហើយឈ្មោះ [redacted] មានម៉ូតូ ម៉ាក សេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ហើយបច្ចុប្បន្ន ឈ្មោះ លេន ធ្វើសំណង់នៅអ៊ុំអន។

៦.ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺសាក្សីឈ្មោះ [redacted] ថា÷ កន្លងមកខ្ញុំបាទ និងជនរង គ្រោះឈ្មោះ [redacted] ដាងជុង បានស្គាល់គ្នារយៈពេល៤ (បួន) ខែ មកហើយតាមរយៈផឹកកាហ្វេនៅម្ដុំ ច្រាំងបាក់ (ច្បារអំពៅ) ហើយគាត់បានរកកម្មករធ្វើសំណង់ដោយជនរងគ្រោះសួរខ្ញុំបាទថា ចេះខាងរ៉ៃ ពុម្ពទេ យក០១ (មួយ) ម៉ែត្រការ៉េ ប៉ុន្មានដុល្លារ? ខ្ញុំឆ្លើយថា បើខ្នាតធំយក២៦ (ម្ភៃប្រាំមួយ) ដុល្លារអាមេ រិក ក្នុង០១ (មួយ) ម៉ែត្រការ៉េ ។ បន្ទាប់មក ជនរងគ្រោះបានទទួលខ្ញុំបាទឱ្យទៅធ្វើសំណង់ នៅចំកាដូង ដែលមានគ្នាចំនួន០៧ (ប្រាំពីរ) នាក់ ដូចជាឈ្មោះ [redacted] ជនជាតិខ្មែរ នៅខេត្តស្វាយរៀង, ឈ្មោះ [redacted] និង ប្រពន្ធជនជាតិខ្មែរ នៅខេត្តស្វាយរៀង, ឈ្មោះ រ៉េត ជនជាតិខ្មែរ នៅខេត្តស្វាយរៀង, ឈ្មោះ ឡុត ជន ជាតិខ្មែរ នៅខេត្តស្វាយរៀង, ឈ្មោះ ពុធ ជនជាតិខ្មែរ នៅខេត្តស្វាយរៀង និងឈ្មោះ សិទ្ធ ជនជាតិខ្មែរ នៅខេត្តស្វាយរៀង ដោយជនរងគ្រោះបើកលុយឱ្យកម្មករគ្រប់ចំនួនពុំដែលមានបញ្ហាទេ។ ក្រោយមក នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ ជនរងគ្រោះបានដកកម្លាំងកម្មករខាងលើ មកធ្វើសំណង់នៅការ៉ាស

សាំងឲ្យឈ្មោះ [redacted] ថុនា នៅភូមិអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ដែលម៉ៅការបន្តពីឈ្មោះ [redacted] ប៊ុនស្រេង លេខទូរស័ព្ទ០៧៧ ៤៩៨ ៨៩៩/០១៥ ៨៤០ ៧០៧ ដោយខាងជនរងគ្រោះមានកម្មករចំនួន ០៨ (ប្រាំបី) នាក់ ក្នុងនោះមានឈ្មោះ [redacted] យ៉ាំងឡុង, ឈ្មោះ [redacted] យ៉ាំងទ្រាង និងកម្មករចំនួន០៤ នាក់ទៀតមិនស្គាល់ឈ្មោះ ហើយក្នុងដំណើរសាងសងនេះ ជនរងគ្រោះពុំនៅការដ្ឋានទេ ជួនកាល០២ (ពីរ) ថ្ងៃ,មួយអាទិត្យ ឬកន្លះខែ ទើបមកមើលកម្មករម្តង។ ប៉ុន្តែប្រាក់បើកឲ្យកម្មករទៀងទាត់ពុំដែលមាន បញ្ហាជាមួយកម្មករទេ។ មកដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ខ្ញុំបាទបានតេទូរស័ព្ទទៅជនរងគ្រោះ សូម ខ្ចីលុយខ្លះដោះស្រាយជីវភាព កម្មករគាត់ឆ្លើយថា ចាំថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ចាំយកលុយខ្លះពីគាត់ ឲ្យ។ ជនរងគ្រោះច្រើនជិះម៉ូតូ ម៉ាកហុងដាងឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២០ មកម្នាក់ឯង។ នៅថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០២១ វេលាម៉ោង០៨ និង២៦ នាទី ខណៈពេលខ្ញុំបាទកំពុងធ្វើការ ស្រាប់តែឈ្មោះ [redacted] យ៉ាំងទ្រាង ជាប្អូនថ្លៃរបស់ជនរងគ្រោះបានមកប្រាប់ខ្ញុំបាទថា បងដុងស្លាប់ហើយ ទើបខ្ញុំសួរថា មូល ហេតុអ្វី? ហើយឈ្មោះ ទ្រាង ឆ្លើយថា ប្រពន្ធជនរងគ្រោះបានតេទូរស័ព្ទប្រាប់គាត់ថា ប៉ូលីសគេប្រាប់ ហើយខ្ញុំបាទបានសួរបន្តទៀតថា គាត់ស្លាប់នៅកន្លែងណា? ឈ្មោះ ទ្រាង បានឆ្លើយថា នៅខេត្តកណ្តាល ប៉ុន្តែខ្ញុំបាទមិនអស់ចិត្ត ទើបនាំគ្នាទៅសួរម្ចាស់ផ្ទះឈ្មោះ មិថុនា ហើយម្ចាស់ផ្ទះបានតេទូរស័ព្ទទៅប៉ូលីស គេប្រាប់ថា មិនមែនស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍នោះទេ។ ប៉ូលីសបន្តទៀតថា នៅឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល រួចមកខ្ញុំបាទ និងឈ្មោះ [redacted] យ៉ាំងទ្រាង បាននាំគ្នាទៅកន្លែងកើតហេតុ ឃើញសពឈ្មោះ [redacted] ដាងដុង ស្លាប់ដោយសារគេចាក់សម្លាប់ពិតប្រាកដមែន។

៧. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ជា ថា÷ ខ្ញុំបាទបានមកធ្វើការ សំណង់នៅភូមិពោង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល រយៈពេល០១ (មួយ) ខែ ០៤ (បួន) ថ្ងៃមកហើយ ផ្នែករៀបឥដ្ឋ។ កម្មករធ្វើការនៅទីនេះ មានគ្នាចំនួន១២ (ដប់ពីរ) នាក់ ដោយកម្មករមកពីរ ភូមិពោង ឃុំសំបួរមាស ចំនួន០៧ (ប្រាំពីរ) នាក់ និងអ្នកមកពីស្រុកខ្សាច់កណ្តាល ចំនួន០៥ (ប្រាំ) នាក់។ កម្មករដែលស្នាក់នៅក្នុងការដ្ឋានមានចំនួន០២នាក់ គឺខ្ញុំបាទ និងឈ្មោះ [redacted] លីន ហៅ តយ។ នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ល្ងាច ដល់ម៉ោង០១យប់ គឺមានភ្លៀង ពេលខ្ញុំបាទសំងំដេកនោះ មានពេលខ្លះលក់ ប៉ុន្តែមានពេលខ្លះរលឹកពីគេង។ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ខ្ញុំបាទពុំបានឮសួរ សំលេងអ្វីទេ។ សំលេងម៉ូតូដែលគេបើកតាមផ្លូវខ្ញុំបាទឮ ប៉ុន្តែសំលេងមនុស្សខ្ញុំបាទពុំឮទេ។ លុះដល់ ពេលព្រឹក ខ្ញុំបាទភ្ញាក់ពីដេកក៏បានឃើញ មនុស្សជុំៗ នៅផ្លូវថ្នល់ចំងាយពីការដ្ឋានប្រហែលជាង២០០ (ពីររយ) ម៉ែត្រ ខ្ញុំគិតក្នុងចិត្តថា គ្រោះថ្នាក់ចរាចរណ៍ ហើយខ្ញុំបាទពុំបានទៅមើលទេ ដោយសារខ្ញុំបាទ កំពុងធ្វើការ។ លុះដល់ម៉ោង០៧ព្រឹក ទើបដឹងថា មានមនុស្សស្លាប់ដោយសារគេចាក់សម្លាប់។ ខ្ញុំដឹងតាម កម្មករនៅក្នុងភូមិពោង ធ្វើការជាមួយគ្នាប្រាប់។ ចំពោះរឿងហេតុអ្វីទៀតខ្ញុំបាទពុំបានដឹងទៀតទេ។

៨. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] គន្ធា ថា÷ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ និង១៧នាទី ខ្ញុំបាទបានធ្វើដំណើរពីផ្ទះ ស្ថិតនៅភូមិព្រែកឬស្សី ឃុំសំបួរមាស

បំណងមកមើលស្រែនៅភូមិអំពិលទឹក ឃុំសំបួរមាស ពេលដល់កន្លែងកើតហេតុ ខ្ញុំបាទបានឃើញស្បែកជើង ពណ៌ខៀវ នៅលើចិញ្ចើមផ្លូវ ត្រង់ចំណុចចំការស្វាយរបស់ឈ្មោះ [redacted]រី ស្ថិតនៅភូមិអំពិលទឹក ក៏បានជួបជាមួយឈ្មោះ [redacted] សុខឡា ហៅ ខាវ, ឈ្មោះ [redacted] ស្រី, ឈ្មោះ [redacted] ងួន ភេទប្រុស និងម្នាក់ទៀតរស់នៅភូមិអំពិលទឹក តែខ្ញុំបាទមិនបានស្គាល់ឈ្មោះទេ។ ឈ្មោះ [redacted] សុខឡាង ហៅ ខាវ សួរខ្ញុំបាទថា មានឃើញខ្មោចងាប់នៅស្រែប្រាំងពូណាកអត់? ទើបខ្ញុំបាទបានតបទៅវិញថា ឃើញតែស្បែកជើង០១(មួយ) គូរទេ។ បន្ទាប់មកឈ្មោះ [redacted] សុខឡាង ហៅ ខាវ ក៏បានឡើងលើម៉ូតូជិះទៅទាំងអស់គ្នា ពេលធ្វើដំណើរជិះទៅដល់កន្លែងកើតហេតុ ចម្ងាយប្រហែល២០០ (ពីររយ) ម៉ែត្រ ក៏ឃើញម៉ូតូចំនួន០២ (ពីរ) គ្រឿង មានគ្នាចំនួន០៣ (បី) នាក់ បានបើកម៉ូតូមកពីទិសខាងលិចឈប់រើសស្បែកជើង ពណ៌ខៀវ ចំនួន០១(មួយ) គូរនៅខាងត្បូងផ្លូវ រួចក៏បានជិះបញ្ច្រាស់កាត់មុខពួកខ្ញុំ ដោយអ្នកទាំង០៣ (បី) នាក់ មានពាន់មួកសុវត្ថិភាព ហើយបានស្លៀកពាក់ខោរអាវចាស់ៗ ដូចអ្នកធ្វើសំណង់។ បន្ទាប់ពីពួកខ្ញុំបានជិះម៉ូតូដល់កន្លែងកើតហេតុ ក៏ឃើញសាកសពងាប់ផ្កាប់មុខនឹងជើង ខ្ញុំបាទមើលសាកសពបានប្រហែល១០ នាទី ខ្ញុំក៏បានជិះម៉ូតូចេញទៅស្រែតែម្តង។

៩. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] លីន ថា÷ ខ្ញុំបាទធ្វើការសំណង់នៅភូមិពោង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល បានរយៈពេលប្រហែល០១(មួយ) ឆ្នាំមកហើយ ដោយខ្ញុំបាទធ្វើការងារខាងរៀបឥដ្ឋ។ កម្មករសរុបមានចំនួន១២ (ដប់ពីរ) នាក់ ដែលធ្វើការនៅជាមួយខ្ញុំបាទ ហើយមានកម្មករស្រីចំនួន០១ (មួយ) ដោយនៅក្នុងចំណោមកម្មករទាំងអស់ មានអ្នករស់នៅស្រុកខ្សាច់កណ្តាលចំនួន០៤ (បួន) នាក់ គឺមានខ្ញុំបាទ, ឈ្មោះ [redacted] ជា ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅភូមិរកាជន្លឹង ឃុំរកាជន្លឹង, ឈ្មោះ [redacted] លី ភេទប្រុស អាយុ២០ឆ្នាំជាង រស់នៅភូមិរកាជន្លឹង ឃុំរកាជន្លឹង, ឈ្មោះ [redacted]រ៉ា ភេទប្រុស អាយុប្រហែលជា២០ឆ្នាំ រស់នៅភូមិរកាជន្លឹង ឃុំរកាជន្លឹង ហើយអ្នកដែលសម្រាកពេលយប់នៅកន្លែងធ្វើការមានចំនួន០២(ពីរ) នាក់ គឺខ្ញុំបាទ និងឈ្មោះ [redacted] ជា ។ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៧ព្រឹក រហូតដល់ម៉ោង០៥ ល្ងាច ក្រុមកម្មករពួកខ្ញុំធ្វើការទាំងអស់គ្នាធម្មតា រហូតដល់ម៉ោង១១យប់ ដោយមានភ្លៀងខ្លាំង ខ្ញុំបាទមិនបានចេញទៅណាទេ។ លុះនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ព្រឹក ខ្ញុំបាទឃើញមានប្រជាជនផ្អើលឆោឡោថាមានមនុស្សស្លាប់នៅជិតកន្លែងខ្ញុំធ្វើការ។

១០. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ស្រី ថា÷ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង៦ និង៣០នាទី ឈ្មោះ [redacted] ងួន ភេទប្រុស បានតេទូរស័ព្ទលេខ ០៩៦ ៦៨០ ៦១៧១ ប្រាប់ខ្ញុំបាទថា ពូមានដឹងរឿងខ្មោចងាប់នៅម្តុំត្នោតជ្រុំ ស្ថិតនៅភូមិពោង ឃុំសំបួរមាស ឬអត់ទេ? ទើបខ្ញុំបាទឆ្លើយថា ដឹងអី ទៅមើលមើ។ បន្ទាប់មក ខ្ញុំបាទក៏បានជិះម៉ូតូឌុបឈ្មោះ [redacted] ងួន ទៅកន្លែងកើតហេតុ ក៏បានឃើញសាកសពអង្គុយផ្កាប់មុខនឹងជើងនៅខាងលិចផ្លូវ។ ឃើញដូច្នេះ ខ្ញុំបាទក៏បានតេទូរស័ព្ទទៅលោក [redacted] ឡាច ជានាយរងប៉ុស្តិ៍។ មួយសន្ទុះក្រោយមក ខ្ញុំបាទឃើញឈ្មោះ [redacted] ខាវ ភេទ

ប្រុស និងប្រជាពលរដ្ឋតែងតែមកឈប់ជាបន្តបន្ទាប់ ហើយខ្ញុំបាទក៏បានយកធាងត្នោតងាប់ៗ យកមកដាក់ជុំវិញសាកសព។ ក្នុងនោះដែរ ខ្ញុំបាទបានឮប្រជាពលរដ្ឋនិយាយថា ឃើញមានមនុស្ស០៣ (បី) នាក់ជិះម៉ូតូមករើសស្បែកជើងនៅកន្លែងកើតហេតុ និងបានជិះម៉ូតូឆ្ពោះទៅទិសខាងលិចបាត់ទៅ។ បន្ទាប់មកខ្ញុំបាទបានឃើញសមត្ថកិច្ច និងប្រជាពលរដ្ឋមកមើលកន្លែងកើតហេតុតែម្តង។

១១. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុវាត ថា÷ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជាង០៦ព្រឹក ខ្ញុំបាទបានបើកម៉ូតូការ៉េមចេញពីផ្ទះ ស្ថិតនៅភូមិព្រៃកប្ញស្សី ឃុំសំបួរមាស មកឡើងត្នោតនៅចំណុចម្តុំត្នោតជ្រុំ នៅខាងលិចកន្លែងកើតហេតុចំងាយប្រហែលជាង១០០ (មួយរយ)ម៉ែត្រ ដោយឃើញមានម៉ូតូឡានជិះឆ្លងកាត់តាមផ្លូវចុះឡើងក៏មិនបានចាប់អារម្មណ៍ទេ។ បន្ទាប់មក ខ្ញុំបាទបានមើលពីលើដើមត្នោត ឃើញស្បែកជើងចំនួន០១ (មួយ) គូរ មិនច្បាប់ពណ៌ទេ នៅលើផ្លូវ។ ក្រោយពីបានឡើងត្នោតបានចំនួន០២ (ពីរ) ដើម ខ្ញុំបាទបានឃើញមនុស្សចំនួនប្រហែលជាង១០ (ដប់) នាក់ ជិះម៉ូតូចំនួន០៥ (ប្រាំ) គ្រឿង កំពុងឈប់ជុំៗគ្នានៅកន្លែងកើតហេតុ។ ឃើញដូច្នេះ ខ្ញុំបាទបានជិះម៉ូតូទៅមើលជាមួយគេ ក៏បានឃើញមានសាកសពអង្គុយអោនក្បាល។ មួយសន្ទុះក្រោយមក ក៏មានប្រជាពលរដ្ឋ និងសមត្ថកិច្ចបានមកមើលជាបន្តបន្ទាប់។ ក្រៅពីនេះខ្ញុំបាទពុំបានឃើញ និងដឹងអ្វីទៀតទេ។

១២. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុខឡាង ថា÷ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០២រសៀល មិត្តភក្តិរបស់ខ្ញុំបាទឈ្មោះ [redacted]រ៉ុន ភេទប្រុស នៅភូមិពោង ឃុំសំបួរមាស បានតេទូរស័ព្ទតាមលេខ ០៦៩ ៧៧៥ ០៣៩ ហើយខ្ញុំបាទបានទៅផឹកស៊ីនៅចំការឈូក ស្ថិតនៅមុខកន្លែងកើតហេតុចម្ងាយប្រហែល១០០(មួយរយ) ម៉ែត្រ ក្នុងពេលនោះមានគ្នាចំនួន១១ (ដប់មួយ) នាក់ ឈ្មោះ [redacted] រ៉ុន និងប្រពន្ធឈ្មោះ [redacted]ចំរើន, ឈ្មោះ គោ និងប្រពន្ធឈ្មោះ [redacted] រ៉ា នៅភូមិពោង, ឈ្មោះ [redacted] គឿន ភេទប្រុស នៅភូមិព្រៃកប្ញស្សី ឃុំសំបួរមាស, ឈ្មោះ [redacted] ភេទប្រុស នៅម្តុំក្តីចាស់, ឈ្មោះ [redacted] ថេត ភេទប្រុស ភូមិអំពិលទឹក ឃុំសំបួរមាស, ឈ្មោះ អៀម ភេទប្រុស នៅចំណុចព្រៃកតាព្រាប ភូមិអន្លង់ស្លែង ឃុំសំបួរមាស, ឈ្មោះ អៀម និងម្នាក់ទៀត ភេទប្រុសមិនស្គាល់ឈ្មោះ បានផឹកស៊ីរហូតដល់ម៉ោង០៥ ឈ្មោះ [redacted] គឿន, ឈ្មោះ ថេត,ឈ្មោះ អឿន, ឈ្មោះ អៀន និងមិត្តភក្តិ បាននាំគ្នាចេញបន្តបន្ទាប់ នៅផឹកបន្តតែខ្ញុំបាទ និងឈ្មោះ [redacted] សារ៉ុន ភេទប្រុស រួមជាមួយប្រពន្ធ ទើបតែមកដល់ រហូតដល់ម៉ោង០៨ យប់ ក៏ឈប់ផឹក ហើយក៏បានជិះម៉ូតូឆ្លងកាត់កន្លែងកើតហេតុដែរ ប៉ុន្តែពុំឃើញមានអ្វីទេ។ លុះនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៥ និង៤០នាទី ខ្ញុំបាទបានក្រោកពីគេងក៏ទៅភ្ជួរស្រែនៅចំណុចខាងកើតពីកន្លែងកើតហេតុប្រហែល៧០០ (ប្រាំពីររយ) ម៉ែត្រ ហើយក៏បានភ្ជួរបង្ហើយស្រែ លុះពេលម៉ាស៊ីនអត់ប្រេង ខ្ញុំបាទបានដើរត្រឡប់មកផ្ទះវិញ ពេលដើរមកដល់ចំណុចដីចម្ការរបស់ឈ្មោះ យាយ រី ក៏បានជួបជាមួយឈ្មោះ អន ភេទប្រុស, ឈ្មោះ [redacted] ស្រី, ឈ្មោះ [redacted] ងួន ភេទប្រុស, ឈ្មោះ គន្ធា ភេទប្រុស ក៏បានឮព័ត៌មានថា មានម៉ូតូដួលនៅចំណុចត្នោតជ្រុំ ឃើញ

ស្បែកជើងនៅលើផ្លូវ។ បន្ទាប់មក ខ្ញុំបាទក៏នាំគ្នាទៅមើលនៅកន្លែងកើតហេតុ ពេលជិះទៅដល់កន្លែងកើតហេតុចម្ងាយប្រហែលជាង១០០ (មួយរយ) ម៉ែត្រ ខ្ញុំបាទបានឃើញម៉ូតូចំនួន០២ (ពីរ) គ្រឿង មានគ្នាចំនួន០៣ (បី) នាក់ មានពាក់ម៉ាស និងមួកសុវត្ថិភាពកំពុងរើសស្បែកជើងនៅលើផ្លូវមុខកន្លែងកើតហេតុ ហើយក៏បានជិះម៉ូតូបញ្ច្រាស់ផ្លូវឆ្ពោះមកភូមិអំពិលទឹក ឃុំសំបួរមាស។ បន្ទាប់មក ពួកខ្ញុំបាទក៏បានទៅដល់កន្លែងកើតហេតុ ឃើញសាកសពអង្គុយស្លាប់ នៅពេលនោះខ្ញុំបាទក៏ស្រែកហៅឈ្មោះ [redacted] សារ៉ុន និងប្រពន្ធថា មានមនុស្សស្លាប់នៅខាងមុខហ្នឹង ទើបពីរនាក់ប្តីប្រពន្ធនោះក៏បានដើរមកមើល។ មួយសន្ទុះក្រោយមក ក៏ឃើញមានប្រជាពលរដ្ឋ និងសមត្ថកិច្ចមកកន្លែងកើតហេតុតែម្តង។

១៣. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted]វ៉ាន់ឌី ថា÷ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦ និង៣០នាទីព្រឹក ខ្ញុំបាទបានចេញពីផ្ទះនៅភូមិស្វាយរំពារ ឃុំស្វាយអំពារ ស្រុកមុខកំពូល មានបំណងទៅធ្វើការនៅភ្នំពេញ ពេលមកដល់ចំណុចម្តុំដើមត្នោតជ្រៃ វេលាម៉ោងជិត០៧ ក៏បានឃើញមានមនុស្សជុំគ្នា ខ្ញុំបាទក៏ជិះទៅមើល ស្រាប់តែឃើញសាកសពអង្គុយផ្កាប់មុខស្លាប់ ពេលនោះខ្ញុំបាទក៏សួរអ្នកនៅទីនោះថា ចឹនឹងបង? ទើបអ្នកនៅទីនោះបានឆ្លើយថា គាត់អត់ដឹងទេគ្រាន់តែឃើញក្មេងចំនួន០៣ (បី) នាក់ ជិះម៉ូតូម៉ាកសង់មករើសស្បែកជើងនៅកន្លែងហ្នឹង។ បន្ទាប់មកខ្ញុំបាទក៏ទូរស័ព្ទទៅលោកអធិការស្រុកមុខកំពូលផ្តល់ដំណឹងឱ្យទៅគាត់ ខ្ញុំបាទក៏ជិះម៉ូតូទៅធ្វើការនៅភ្នំពេញបាត់ទៅ។ លុះវេលាម៉ោង០៦ និង៣០នាទី មានទូរស័ព្ទលេខ ០១២ ៥៥២ ៧២៥ បានគេសួរខ្ញុំថា កន្លែងកើតហេតុនៅឯណា? ខ្ញុំបាទបានឆ្លើយថា កន្លែងកើតហេតុនៅភូមិអំពិលទឹក ឃុំសំបួរមាស បន្ទាប់មក គាត់ក៏ឆ្លើយថាអូខេ នៅវេលាម៉ោង០៨ និង៣១នាទី ក៏មានលេខទូរស័ព្ទ ០១២ ៦៣២ ៦០៩ បានទូរស័ព្ទឱ្យខ្ញុំបាទមកបំភ្លឺ ខ្ញុំបាទក៏បានទៅតាមការហៅរបស់គាត់តែម្តង។

១៤. ក្រឡាបញ្ជីអានពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ធីយ៉ាវ។

១៥. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ÷ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ, ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី រួមទាំងការពិនិត្យភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿងរួចមក ឃើញថា ជនជាប់ចោទឈ្មោះ ស្រេង ឆាយ ពិតជាប្រព្រឹត្តអំពើ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ប្រាកដមែន។ ទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធគ្រប់ដំណាក់កាលទាំងអស់ថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ក៏ដោយ ក៏ជនជាប់ចោទពុំមានភស្តុតាង និងសាក្សីមកបញ្ជាក់នៅចំពោះមុខតុលាការឡើយ។ ឃើញថា ជនជាប់ចោទមិនភ្ញាក់រលឹក និងទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្តឡើយ។ ហេតុនេះ នាងខ្ញុំស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទពីបទ ឃាតកម្មគិតទុកជាមុន ស្របតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ។

១៦. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា÷ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួមមក ឃើញថា កន្លងមកកូនក្តីខ្ញុំបាទបានឆ្លើយបដិសេធ



Scanned with CamScanner

រាល់ចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ព្រោះថាចម្លើយនោះកូនក្តីខ្ញុំអះអាងថាដោយសារមានការបង្ខិតបង្ខំ និងប្រើអំពើហិង្សា។ ចំពោះចម្លើយរបស់កូនក្តីខ្ញុំបាទនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការនេះ កូនក្តីខ្ញុំបាទនៅតែបដិសេធថាខ្លួនមិនបានសម្លាប់ជនរងគ្រោះឡើយ ប៉ុន្តែខ្លួន និងជនរងគ្រោះពិតជាបានឈ្លោះប្រកែកគ្នា និងបានវាយតប់គ្នាដៃ និងដៃប្រាកដមែន។ នាពេលសវនាការនេះ កូនក្តីខ្ញុំបាទក៏បានបញ្ជាក់ដែរថា គាត់មិនធ្លាប់មានបំណងចង់សម្លាប់ជនរងគ្រោះឡើយ។ ហេតុនេះ ខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំបាទរួចផុតបទចោទប្រកាន់ផង។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] តាយ
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីនានា
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុផ្សេងៗនៅក្នុងសំណុំរឿង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង
- ក្រោយពីបានពិនិត្យ និងពិភាក្សាក្នុងក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. យល់ឃើញថា កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ មានករណី ឃាតកម្មគិតទុកជាមុន ស្ថិតនៅចំណុចភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ ស្រេង តាយ ភេទប្រុស ដែលបានតេណាត់ជួបជនរងគ្រោះឈ្មោះ [redacted] ដាងជុង ភេទប្រុស មកជួបដើម្បីនិយាយពីរឿងការងារថ្មី ប៉ុន្តែជនរងគ្រោះបានឱ្យជនជាប់ចោទរងចាំជាច្រើនម៉ោង ទើបបណ្តាលឱ្យជនជាប់ចោទខឹង។ លុះក្រោយមក អ្នកទាំងពីរបានទៅកន្លែងណាត់ជួបពិភាក្សាការងារ ប៉ុន្តែជនរងគ្រោះបានប្រាប់ជនជាប់ចោទថា អ្នកដែលនិយាយការងារអត់មកទេ ទើបធ្វើឱ្យជនជាប់ចោទខឹង និងឈ្លោះគ្នា។ លុះដល់ម៉ោង២០ និង៣០នាទី ជនរងគ្រោះបានឌុបជនជាប់ចោទបានចម្ងាយ៣,៥ គីឡូម៉ែត្រ ពីកន្លែងផឹកស៊ី ហើយជនរងគ្រោះបានឈប់នោមនៅចំណុចភូមិអំពិលទឹក ស្រាប់តែឈ្មោះ [redacted] តាយ បានយកកូនកាំបិតដងជ័រ ពណ៌លឿង ដែលលាក់ទុកក្នុងហោប៉ៅខោដែលត្រៀមជាស្រេចនោះ ចាក់ខ្នងជនរងគ្រោះចំនួន០១ (មួយ) កាំបិត ត្រូវចំដើមទ្រូងខាងឆ្វេងចំនួន០១ (មួយ) កាំបិត និងបានចាក់ពីលើខ្នងជាច្រើនកាំបិតទៀតបណ្តាលឱ្យជនរងគ្រោះស្លាប់ និងបានយកម៉ូតូជនរងគ្រោះទៅចោលក្នុងទឹកតែម្តង។ លុះដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ទើបកម្លាំងជំនាញកងរាជអាវុធហត្ថបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] តាយ និងកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី ។

២. យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] តាយ បានបញ្ជាក់ថា÷ ខ្លួន និងជនរងគ្រោះឈ្មោះ [redacted] ដាងជុង គឺជាមិត្តភក្តិនឹងគ្នាតាំងពីនៅតូច រហូតដល់បច្ចុប្បន្នក៏រកស៊ី ធ្វើការជាមួយគ្នាដែរ។ នៅថ្ងៃកើតហេតុ ខ្លួន និងជនរងគ្រោះឈ្មោះ [redacted] ដាងជុង បានឈ្លោះប្រកែកគ្នារឿងការងារនៅកន្លែងហាងផឹកស៊ីមួយកន្លែង។ បន្ទាប់មក ជនរងគ្រោះបានជិះម៉ូតូឌុបខ្លួនចេញពីហាងផឹកស៊ីនោះសំដៅទៅផ្ទះវិញបានប្រហែលជាដប់នាទី ក៏ឈ្លោះគ្នាទៀត នឹងបានឈប់ម៉ូតូ ពេលនោះខ្លួនក៏បានវាយទៅលើជនរងគ្រោះចំនួនបីទៅបួនដៃ ហើយជនរងគ្រោះក៏បានយកមួកសុវត្ថិភាពវាយមកលើរូបខ្លួនវិញដែរ។ ប៉ុន្តែខ្លួនមិនបានយកកាំបិតចាក់ជនរងគ្រោះឡើយ។ ពេលខ្លួនវាយជនរងគ្រោះបណ្តាលឱ្យដួលផ្កាប់មុខរួច ខ្លួនក៏លើកម៉ូតូរបស់ជនរងគ្រោះជិះទៅផ្ទះតែម្តង។ បន្ទាប់មក ខ្លួនបានយកម៉ូតូនោះទៅដាក់បញ្ចាំ ប៉ុន្តែដោយសារតែខ្លាចគេសង្ស័យ ខ្លួនក៏យកម៉ូតូនោះទៅទំលាក់ទឹកចោល។ ខ្លួនសូមបដិសេធចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច, ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ចោលទាំងស្រុង។ នៅក្នុងរឿងនេះ ខ្លួនមិនធ្លាប់មានចេតនាចង់សំលាប់ជនរងគ្រោះឡើយ។

៣. យល់ឃើញថា ផ្អែកតាមចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ ឃើញថា ជនជាប់ចោទរូបនេះ នៅតែឆ្លើយបដិសេធថារូបគេមិនបានយកកាំបិតចាក់សម្លាប់ជនរងគ្រោះឡើយ ដែលចម្លើយនេះ ផ្ទុយនឹងចម្លើយដែលជនជាប់ចោទធ្លាប់បានឆ្លើយកាលពីនៅដំណាក់កាលសមត្ថកិច្ចថា ពេលជិះម៉ូតូមកតាមផ្លូវរូបគេបានដកយកកូនកាំបិតចុងស្រួច ដងជ័រ ពណ៌លឿង ដែលលាក់ទុកក្នុងហោប៉ៅខោ ទាញយកមកចាក់អាជុង ០១ (មួយ) កាំបិត ចំខ្នងពីក្រោយ។ ភ្លាមនោះ វាក៏បានយកមួយសុវត្ថិភាពរត់ដេញវាយមកលើខ្លួនវិញចំនួន០២ម្តង ត្រូវចំក្បាល ហើយខ្លួនក៏បានរត់ទៅមុខ តែ អាជុង បានដេញតាមបន្តទៀត ខ្លួនក៏បានបែក្រោយមកចាក់វាត្រូវចំនួន០១ (មួយ) កាំបិតទៀត ខាងមុខ (មិនដឹងត្រូវដើមទ្រូង ឬពោះទេ) ពេលនោះ អាជុង បានដួលនៅក្បែរចិញ្ចើមផ្លូវ រួចខ្លួនក៏បានចាក់បន្ថែមពីលើខ្នងវាជាច្រើនកាំបិតទៀត រួចហើយក៏ប្រញាប់លើកម៉ូតូរបស់វាជិះត្រឡប់ក្រោយ គេចខ្លួន និងគប់កូនកាំបិតចោលនៅម្តុំនោះ ជិះគេចចេញទៅផ្លូវជាតិលេខ៦A ឡើងស្ពានព្រែកតាម៉ាក់ តាមផ្លូវជាតិលេខ៨ ដល់រង្វង់មូលស្វាយអន្ទរបត់ស្តាំ ពេលនោះពាក់កណ្តាលផ្លូវ ខ្លួនបានកាច់ស្លាកលេខម៉ូតូ និងកញ្ចក់បោះចោល (មិនចាំកន្លែង) ហើយជិះបន្តមកដល់អ្នកលឿង ហើយបានយកម៉ូតូនោះទៅដាក់បញ្ចាំ។ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២០ ខ្លួនបានទៅលោះម៉ូតូនោះមកវិញ រួចបានយកម៉ូតូនោះទៅទំលាក់ចោលនៅស្រះទឹកក្នុងវត្ត ទួលសមាធិ ដើម្បីបំបាត់ភស្តុតាង ហើយមកផ្ទះវិញធ្វើដូចមិនដឹងរឿងអ្វីទាំងអស់។ តាមរយៈកំណត់ហេតុស្តាប់ចម្លើយជនសង្ស័យឈ្មោះ ស្រេង តាយ កាលពីនៅដំណាក់កាលសមត្ថកិច្ច អាចបញ្ជាក់បានយ៉ាងច្បាស់ថាចម្លើយដែលជនជាប់ចោទឆ្លើយនាពេលសវនាការនេះ គឺគ្រាន់តែជាចម្លើយឆ្លើយដោះសារ ដើម្បីឱ្យខ្លួនរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ។ ជនជាប់ចោទរូបនេះ មានចេតនា និងមានគំរោងប្រព្រឹត្តបទល្មើសរហូតដល់បានសម្រេចបំណង និងមិនទទួលស្គាល់កំហុស មិនមានចេតនាចង់កែប្រែខ្លួនឡើងវិញឡើយ ។ មួយវិញទៀត បើប្រៀបធៀបចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលស៊ើបអង្កេត ដំណាក់កាលស៊ើប

សួរ និងដំណាក់កាលជំនុំជម្រះ គឺមានតែជនជាប់ចោទប៉ុណ្ណោះដែលមានទំនាក់ទំនង និងមានវត្តមានជាមួយជនរងគ្រោះដែលស្លាប់ ហើយជនជាប់ចោទក៏បានសារភាពដែរថា បានឈ្លោះប្រកែកជាមួយជនរងគ្រោះ និងឈានដល់ការវាយតប់គ្នាទៅវិញទៅមកនាយប់កើតហេតុនោះ។ លើសពីនេះទៅទៀត តាមចម្លើយសាក្សីនានា បានបញ្ជាក់ថា នៅវេលាម៉ោងប្រហែល៨ និង៣០នាទីយប់ ពេលពួកគេជិះកាត់កន្លែងកើតហេតុ គឺមិនមានរឿងអ្វីកើតឡើងនោះទេ គឺមានសភាពធម្មតា។ ដូចនេះ នៅយប់ថ្ងៃកើតហេតុដែលជាវេលាភ្លៀងធ្លាក់នោះ គឺពុំមានបុគ្គលណាផ្សេងពីជនជាប់ចោទដែលបានយកកាំបិតចាក់សម្លាប់ជនរងគ្រោះនោះទេ ហើយចម្លើយរបស់ជនជាប់ចោទនាពេលសវនាការគឺគ្រាន់តែជាចម្លើយបដិសេធ ដោយគ្មានភស្តុតាង និងសាក្សីមកបញ្ជាក់នោះទេ ដែលចំណុចនេះ គប្បីតុលាការពិចារណាទៅលើចម្លើយសារភាពកន្លងមក ចម្លើយរបស់សាក្សី ព្រមទាំងលទ្ធផលនៃការស៊ើបសួរដែលមាននៅក្នុងសំណុំរឿង។

**៤.យល់ឃើញថា** ផ្អែកតាមសំអាងហេតុចំណុចទី១, ទី២ និងចំណុចទី៣, តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, តាមចម្លើយរបស់សាក្សីដែលមាននៅក្នុងសំណុំរឿង, របាយការណ៍របស់សមត្ថកិច្ចរួមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង គឺអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] តាយ ពិតជាបានប្រព្រឹត្តបទល្មើស ឃាតកម្មគិតទុកជាមុន ពិតប្រាកដមែន។

**៥.យល់ឃើញថា** មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] តាយ ហៅ តាយ ភេទប្រុស កើតឆ្នាំ១៩៨២ (អាយុ៤០ឆ្នាំ) ជនជាតិខ្មែរ ពីបទ÷ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ។

**៦.យល់ឃើញថា** អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់អាយុជីវិតរបស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

**៧.យល់ឃើញថា** ពេលធ្វើសកម្មភាព ជនជាប់ចោទខាងលើមានសតិ បញ្ញា ស្មារតី គ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៨.យល់ឃើញថា ជនរងគ្រោះបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជំងឺចិត្ត និងការខូចខាតពីជនជាប់ចោទ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងចំពោះក្រឡាបញ្ជីតាមរយៈលេខទូរស័ព្ទលេខ០៩៧៦៤៦៦៩៩៦ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ថាខ្លួននៅតែទាមទារសំណងការខូចខាត និងជំងឺចិត្តចំនួន១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឃើញថាការប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានភាពត្រឹមត្រូវតាមច្បាប់ គប្បីតុលាការធ្វើការពិចារណាអំពីទំហំនៃការខូចខាតជាក់ស្តែង ស្របតាមបញ្ញត្តិមាត្រា១៣ និងមាត្រា១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៩.យល់ឃើញថា** វត្ថុតាងដកហូតរួមមាន ទូរស័ព្ទចំនួន០១ (មួយ) គ្រឿង ម៉ាក Huawei ពណ៌ខ្មៅ (មិនប្រក្រតី) ជាវត្ថុតាងដែលបានចាប់យកពីជនជាប់ចោទ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចរឹបអូស ។



Scanned with CamScanner

## ហេតុដូច្នេះ សម្រេចសេចក្តី

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] តាយ ហៅ តាយ ភេទប្រុស កើតឆ្នាំ១៩៨២ (អាយុ ៤០ឆ្នាំ) ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល **អស់មួយជីវិត** ។

ពីបទ÷ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឱ្យឈ្មោះ [redacted]តាយ ហៅ តាយ សងសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីយ៉ាវ ភេទស្រី ។

៣.រឹបអូសវត្ថុតាងរួមមាន ទូរស័ព្ទចំនួន០១ (មួយ) គ្រឿង ម៉ាក Huawei ពណ៌ខ្មៅ (មិនប្រក្រតី)។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា÷ | ហត្ថលេខា និងត្រា÷ | ហត្ថលេខា និងត្រា÷ | ហត្ថលេខា និងត្រា÷ |

[redacted]

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]